**ព្រឹទ្ធសភា**

**អគ្គលេខាធិការដ្ឋាន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣

នៅក្នុងឆ្នាំ២០២២នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

–បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១៣លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៦លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ចំនួន០១លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន១៤ច្បាប់

២-ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភា លើកទី៧ និងលើកទី៨, លើកទី៨ និងលើកទី៩ នីតិកាលទី៤

៣-ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤ ជំនួសលោកជំទាវ ឱ សុខុម ដែលបានទទួលមរណភាព

៤-ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រឹទ្ធសភា នីតិកាលទី៤

៥-ការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន០១រូប ជំនួសសមាជិក ដែលបានទទួលមរណភាព



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
[illegible] (855 23) 211 446 E-mail: oumsarith_sgsenate@gmail.com oumsarith_sgsenate@yahoo.com

-បានរៀបចំចាត់ចែងជូនគណៈកម្មការនានាព្រឹទ្ធសភា ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាលចំនួន ១០លើក ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន១៤ច្បាប់

-បានរៀបចំចាត់ចែងជូនគណៈកម្មការនានាព្រឹទ្ធសភា ប្រជុំពិនិត្យ និងពិភាក្សាការងារជាមួយ ប្រធានគណៈកម្មការទី១ និងទី៣ នៃរដ្ឋសភា, រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ក្រសួងការពារជាតិ, ក្រសួង-កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, គណៈកម្មាធិការសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៃក្រសួងមហាផ្ទៃ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា លើសំណើរបស់តំណាងសហគមន៍ជនជាតិភាគតិច១៦អំបូរ ក្នុងការកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ និងសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិសិទ្ធិមនុស្សកម្ពុជា

-បានរៀបចំជូនសមាជិកព្រឹទ្ធសភា ប្រជុំពិគ្រោះយោបល់ស្តីពី ការបង្កើតគណៈកម្មការពិសេស និងនីតិវិធីការងារ ដើម្បីរៀបចំសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រ-កម្ពុជា

-បានផ្តល់សេវាជូនសមាជិកគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈ-កម្មការច្បាប់ និងនីតិវិធីបោះឆ្នោតស្តីពី ផែនការឆ្ពោះទៅការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។

**២- មុខងារតាមដានការអនុវត្តច្បាប់**

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា៖

+អញ្ជើញជួបសវនាការការងារជាមួយគណៈប្រតិភូក្រសួង ស្ថាប័ននានា រួមមាន៖ ក្រសួង-ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងព័ត៌មាន, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងបរិស្ថាន, អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍, ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្តកោះកុង, មន្ទីរកិច្ចការនារី និងមន្ទីរផែនការរាជធានីភ្នំពេញ, អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ, អនុប្រធានទី១ អាជ្ញាធរអគ្គិសនីកម្ពុជា និងពុទ្ធសាសនបណ្ឌិត្យរាជធានីភ្នំពេញ និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈម ព្រមទាំងការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ

+អញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងចក្ខុវិស័យការអនុវត្តច្បាប់ ការផ្សព្វផ្សាយច្បាប់ និងព័ត៌មាន ពិនិត្យតាមច្រកទ្វារព្រំដែនអន្តរជាតិ និងសម្រង់ព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ, ការពង្រឹងកិច្ចការរដ្ឋបាលឃុំ-សង្កាត់

ក្រោយការបោះឆ្នោតសំដៅអភិវឌ្ឍន៍មូលដ្ឋានជានាបានសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តស្ទឹងត្រែង និងខេត្តមណ្ឌលគិរី

+អញ្ជើញចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តការងារតាមវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ព្រមទាំងជួបសំណេះសំណាលការងារជាមួយគណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ស្មៀន មេភូមិ និងនាយប៉ុស្តិ៍នគរបាល នៅខេត្តតាកែវ ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តស្ទឹងត្រែង ខេត្ត-ក្រចេះ និងខេត្តរតនគិរី

+អញ្ជើញចូលរួមប្រជុំអន្តរក្រសួងស្តីពី វឌ្ឍនភាពនៃការពិនិត្យសិក្សា និងចងក្រងឯកសារទីតាំងដីដែលប្រជាពលរដ្ឋប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែងក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ នៅក្នុងភូមិសាស្ត្រខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ក្រោមអធិបតីភាព ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**៣-មុខងារតំណាង**

–បានរៀបចំចាត់ចែង ផ្តល់សេវា និងអមដំណើរៈ

+**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា

- អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន១៦លើក
- អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន៤០លើក
- ឧបត្ថម្ភថវិកាចំនួន២០,០០០ដុល្លារ និង២០លានរៀល ជូនកាកបាទក្រហមកម្ពុជា និងរាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាមីននៅកម្ពុជា

+**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា** អនុប្រធានទី១ព្រឹទ្ធសភា

- អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន១៥លើក
- អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន១៨លើក

+**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា

- អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន២៤លើក
- អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន៥១លើក
- ឧបត្ថម្ភថវិកាចំនួន២០លានរៀល ជូនដល់កាកបាទក្រហមកម្ពុជា និង១០លានរៀល ឧបត្ថម្ភដល់សាលាបឋមសិក្សាអនុវត្តរាជធានី ដើម្បីកែលម្អបរិស្ថានសាលារៀន

-បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធសម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយអំពីវិធានការសុខាភិបាលស្តីពី វិធីការពារខ្លួនពីជំងឺរាតត្បាតកូវីដ-១៩ ជាពិសេសអំពាវនាវឱ្យប្រជា-ពលរដ្ឋ អញ្ជើញទៅពិនិត្យ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា និងបានបំពេញការកិច្ចផ្សេងៗទៀតនៅមូលដ្ឋានរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន៣,១១៣លើក និងបានចូលរួមពិធីផ្សេងៗចំនួន៦៥៣លើក

-បានរៀបចំវេទិកាស្តីពី ការពង្រឹងសមត្ថភាពដឹកនាំរបស់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ជាស្ត្រីក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ នៅខេត្តសៀមរាប

-បានរៀបចំ និងផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារទីចាត់ការចំនួន០១ខ្នង អគារសិក្សាថ្មីចំនួន០១ខ្នង និងអគាររដ្ឋបាលវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅខណ្ឌជ្រោយចង្វាររាជធានីភ្នំពេញ

-បានសហការរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមក្នុងពិធីបុណ្យជាតិ-អន្តរជាតិ និងពិធីសាសនាចំនួន០៨លើក

-បានសហការរៀបចំជូនសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបពិភាក្សា សិក្ខាសាលា បទបង្ហាញ ពិធីផ្សព្វផ្សាយ និងកម្មវិធីផ្សេងៗចំនួន១០៨លើក

-ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចុះធ្វើការងារសង្គមកិច្ចជួយប្រជាពលរដ្ឋនៅសង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញចំនួន២០លើក

-ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីពិនិត្យវឌ្ឍនភាពនៃការកសាងសមត្ថភាពសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានជាប់ឆ្នោតអាណត្តិទី៥ និងកិច្ចការផ្សេងៗ ព្រមទាំងបានឧបត្ថម្ភសៀវភៅសរសេរចំនួន៦,២០០ក្បាល ដើម្បីចែកជូនសិស្សានុសិស្សដែលកំពុងខ្វះខាតក្នុងមូលដ្ឋានក្នុងថ្ងៃបើកបវេសនកាលឆ្នាំសិក្សាថ្មី នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-បានរៀបចំជូនសមាជិកព្រឹទ្ធសភា និងឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា

ព្រមទាំងក្រុមការងាររបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះទៅពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃ ជូនប្រជាពលរដ្ឋក្រីក្រ នៅរាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ

–បាននាំយកអំណោយរបស់**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** ប្រធានព្រឹទ្ធសភា ចែកជូនកុមារកំព្រា នៅអង្គការបណ្ដុះបណ្ដាល និងថែរក្សាកុមារកំព្រា និងអង្គការកុមារកំព្រាភូមិថៃ នៅខេត្តកំពង់ស្ពឺ ព្រមទាំងបាននាំយកម៉ាស៊ីនពិនិត្យសម្ពាធបេះដូងចំនួន០១គ្រឿង ម្សៅទឹកដោះគោសម្រាប់ទារក និងកុមារចំនួន៩,៤៧២កំប៉ុង ជូនដល់មន្ទីរពេទ្យជ័យវរ្ម័នទី៧ នៅខេត្តសៀមរាប

–បានផ្ដល់សេវាជូនក្រុមការងាររបស់ឯក**ឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា ចុះសួរសុខទុក្ខ និងនាំយកថវិកាមួយចំនួនជូនឯកឧត្តម **ញៀន គឿន** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ដែលមានជំងឺស្ទះសរសៃឈាមខួរក្បាល និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យជោរ៉ៃភ្នំពេញ

–បានជួបសំណេះសំណាល និងនាំយកអំណោយរបស់សមាគមសប្បុរសធម៌ **បាវយ៉ាកង្វ៉ូ** ទីក្រុងហូជីមិញ ចែកជូនប្រជាពលរដ្ឋជួបការលំបាកចំនួន២០០គ្រួសារ មកពីខេត្តកំពង់ចាម ព្រមទាំងប្រជាពលរដ្ឋរងគ្រោះដោយជំនន់ទឹកភ្លៀងចំនួន១២៣គ្រួសារ នៅខេត្តព្រះវិហារ

–បាននាំយកថវិការបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឧបត្ថម្ភដល់សមាគមចលនាវប្បធម៌ដើម្បីកុមារកំព្រា កុមារក្រីក្រ កាកបាទក្រហមកម្ពុជា និងក្រុមគ្រូពេទ្យមកប្រចាំការក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរចំនួន២៦លានរៀល

–លេខាធិការដ្ឋានសមាគមសង្គហៈនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បាននាំយកបច្ច័យចំនួន ២លានរៀល ប្រគេនព្រះភិក្ខុ សច្ចកល្យាណោ **យន់ លីអង** មានអាពាធបេះដូង គង់នៅវត្តទំពូងអង្គចំរើន មានជ័យ ខេត្តកំពង់ស្ពឺ

–បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃចំនួន៨០កញ្ចប់ ក្នុងពិធីបុណ្យមាឃបូជា និងរៀបចំអំណោយចំនួន៦០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

–បានរៀបចំកម្មវិធីសប្បុរសធម៌បរិច្ចាគឈាម សហការជាមួយមជ្ឈមណ្ឌលជាតិផ្ដល់ឈាម នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

–បានរៀបចំពិធីសំណេះសំណាលជាមួយនិវត្តជន, មន្ត្រីរាជការវ័យចំណាស់ និងសន្តិសុខផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

–បានធ្វើបទបង្ហាញស្ដីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនសាស្ត្រាចារ្យ និស្សិត និងសិក្ខាកាមវគ្គបណ្ដុះបណ្ដាលនានាចំនួន១២លើក មានសិក្ខាកាមចូលរួមផ្ទាល់ចំនួន៧០៥នាក់ និងតាម

ប្រព័ន្ធវីដេអូចំនួន៤៧៩នាក់

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន១៣០នាក់

-បានផ្តល់សៀវភៅដែលបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រសួងការពារជាតិ, ប្រធានការិយាល័យគ.ជ.ប, កងរាជអាវុធហត្ថការពារព្រំដែនកម្ពុជា-ឡាវ, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ និងពុទ្ធិកសាកលវិទ្យាល័យចំនួន៥,៥៧១ក្បាល

-បានធ្វើបច្ចុប្បន្នភាព រៀបចំផលិត និងផ្សព្វផ្សាយៈ

+ សៀវភៅស្តីពី សកម្មភាពការងាររបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភាទទួលជួបភ្ញៀវអន្តរជាតិ (ឆ្នាំ២០១៤-២០២១)ចំនួន១០០ក្បាល
+ សៀវភៅទិនានុលេខន៍ឆ្នាំ២០២៣ ចំនួន២,៨០០ក្បាល
+ ប្រតិទិនឆ្នាំ២០២៣ របស់ព្រឹទ្ធសភា ចំនួន២,៥០០ក្បាល និងប្រតិទិនផែនការកម្មវិធីការងារប្រចាំថ្ងៃឆ្នាំ២០២៣ ចំនួន៥០០ក្បាល
+ សៀវភៅបត់ស្តីពី មុខងារនីតិកម្មព្រឹទ្ធសភាចំនួន១,០០០សន្លឹក
+ សៀវភៅបត់ស្តីពី សមាសភាព តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភាចំនួន១,០០០សន្លឹក
+ សៀវភៅបត់ស្តីពី ភាពខុសគ្នារវាងព្រឹទ្ធសភា និងរដ្ឋសភា ចំនួន១,០០០សន្លឹក
+ សៀវភៅបត់ស្តីពី ព្រឹទ្ធសភា នីតិកាលទី៤ (ភាសាខ្មែរ អង់គ្លេស និងភាសាបារាំង) ចំនួន៣,០០០សន្លឹក
+ ស្លាករថយន្តចេញ-ចូលព្រឹទ្ធសភាឆ្នាំ២០២៣ ចំនួន៣,៤០០សន្លឹក
+ ខ្សែវីដេអូសមិទ្ធផលរបស់ព្រឹទ្ធសភាចំនួន០៦ខ្សែ
+ ទស្សនាវដ្តីប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០២២ ចំនួន៩,៦០០ក្បាល
+ សារជូនពររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសពិធីបុណ្យប្រពៃណីជាតិ និងអន្តរជាតិ

-បានរៀបចំសារលិខិតថ្វាយព្រះពរ ជូនពរ អបអរសាទរ និងថ្លែងអំណរគុណរបស់ថ្នាក់ដឹកនាំសមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា, **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ, **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និង

ឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានាចំនួន១០៦លិខិត

–បានរៀបចំ និងផ្ញើសាររំលែកទុក្ខក្នុងនាមថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤១លិខិត និងចូលរួមពិធីគោរពវិញ្ញាណក្ខន្ធ ពិធីបញ្ចុះសព ពិធីបូជាសពរបស់ឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានាចំនួន២២លើក

–បានទទួលពាក្យបណ្ដឹងចំនួន៤៦ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន៤៦ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន៣៧ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន៤១ករណី និងទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្ដឹងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន១២ករណី និងតម្កល់ទុកមិនចាត់ការចំនួន០៥ករណីដោះស្រាយបញ្ចប់ចំនួន០១ករណី និងទទួលឯកសារពាក្យបណ្ដឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបចំនួន៤៣ករណី។

**៤-មុខងារសហប្រតិបត្តិការអន្តរជាតិ**

–បានរៀបចំចាត់ចែង និងផ្ដល់សេវាជូន **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** ប្រធានព្រឹទ្ធសភា៖

+ក្នុងពិធីជូនសារតាំង ជំនួបសម្ដែងការគួរសម សវនាការ និងជម្រាបលា ជាមួយគណៈ-ប្រតិភូជាតិ-អន្តរជាតិ និងអង្គទូតនានាចំនួន៣៣លើក

+អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ទៅបំពេញទស្សនកិច្ចជាផ្លូវការ និងមិត្តភាព នៅសាធារណរដ្ឋកូរ៉េ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

+អញ្ជើញថ្លែងសុន្ទរកថាក្នុងពិធីបើកមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (AIPA-43) ក្រោមមូលបទ "បោះជំហានជាមួយគ្នា ដើម្បីចីរភាព បរិយាប័ន្ន និងភាពធន់របស់អាស៊ាន" នៅសណ្ឋាគារសុខាភ្នំពេញ

+អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធឥស្សរជនជាន់ខ្ពស់បណ្ដាប្រទេសជាមិត្តនានាចំនួន០៣លើក

–បានរៀបចំ និងផ្ដល់សេវាជូន **ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភាក្នុងពិធីជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់ជាតិ និងអន្តរជាតិចំនួន០៥លើក

–បានរៀបចំ សម្រួលបែបបទ ផ្ដល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានា ដោយផ្ទាល់ និងតាមប្រព័ន្ធវីដេអូ រួមមាន៖ អញ្ជើញចូលរួមកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយមហាសន្និបាតសភាតំបន់អាស៊ី(APA) ស្ដីពី ការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងបញ្ហាផ្សេងៗ, កិច្ចប្រជុំសភាតំបន់អាស៊ី(APA),

កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃក្រុមសភាជាតិ(APF), កិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង, កិច្ចប្រជុំគណៈកម្មការសភា (APF), កិច្ចប្រជុំក្រុមទទួលបន្ទុកការស៊ើរើលក្ខន្តិកៈ (APF), កិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក(ASGP), កិច្ចប្រជុំគណៈកម្មាធិការនយោបាយសម្រាប់មហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤៣, កិច្ចប្រជុំពិគ្រោះយោបល់នៃគណៈកម្មាធិការស្ត្រីអាយប៉ា(WAIPA), មហាសន្និបាតសហភាពអន្តរសភាលើកទី១៤៤ (IPU-144), មហាសន្និបាតលើកទី៤៧ នៃសភានិយាយភាសាបារាំង(APF), កិច្ចប្រជុំប្រចាំឆ្នាំរបស់(AIPACODD) លើកទី៥ នៃក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ា ស្តីពីគ្រឿងញៀន, កិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមអ្នកនយោបាយអាយប៉ាលើកទី១៣ ក្រោមប្រធានបទ "ការអនុវត្តលើសេចក្តីសម្រេចនៃមហាសន្និបាតអាយប៉ាលើកទី៤២ និងកិច្ចសហប្រតិបត្តិការលើសេដ្ឋកិច្ចឌីជីថល ក្នុងអាស៊ានក្រោយវិបត្តិកូវីដ-១៩", កិច្ចប្រជុំរបស់វេទិកាអាស៊ីប៉ាស៊ីហ្វិក លើកទី6 (APPFGH6)ស្តីពី សុខភាពសកល, កិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ីប៉ាស៊ីហ្វិក លើកទី៣០ (APPF-30th), កិច្ចប្រជុំលើកទី១០ នៃសភាប្រើភាសាបារាំង(APF), មហាសន្និបាតសហភាពអន្តរសភា លើកទី១៤៥, មហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (ASEAN Inter-Parliamentary Assembly) ក្រោមមូលបទ "បោះជំហានជាមួយគ្នាដើម្បីចីរភាព បរិយាប័ន្ន និងភាពធន់របស់អាស៊ាន", មហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រុមសីលធម៌សមាជិកសភាប្រើភាសាបារាំង, សិក្ខាសាលាស្តីពីពាណិជ្ជកម្មអន្តរជាតិឆ្នាំ២០២២ ព្រមទាំងបានបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋឥណ្ឌា ក្នុងឱកាសខួប៧០ឆ្នាំ នៃមិត្តភាពកម្ពុជា-ឥណ្ឌា និងខួប៣០ឆ្នាំ នៃមិត្តភាពអាស៊ាន-ឥណ្ឌា, ទស្សនកិច្ចការងារនៅសភាសហព័ន្ធវ៉ាល់ឡូនី ព្រុចសែល ព្រះរាជាណាចក្របែលហ្ស៊ិក, ទស្សនកិច្ចនៅសមាគមសណ្តែកសៀងអាមេរិក និងទស្សនកិច្ចការងារគណៈប្រតិភូក្រុមមិត្តភាពសភាកម្ពុជាជាមួយរដ្ឋសភាវៀតណាម នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

–បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម សវនាការ និងពិភាក្សាការងារជូនសមាជិក សមាជិកាព្រឹទ្ធសភា ជាមួយភ្ញៀវជាតិ-អន្តរជាតិ និងអង្គទូតនានាចំនួន២៥លើក

–ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យភ្ញៀវជាតិ និងអន្តរជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារចំនួន១១លើក និងបានចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយអគ្គលេខាធិការព្រឹទ្ធសភាបារាំងស្តីពី សហប្រតិបត្តិការបណ្តុះបណ្តាលធនធានមនុស្ស និងពិធីចុះអនុស្សរណៈជាមួយវិទ្យាស្ថានស្រាវជ្រាវច្បាប់នៃសាកលវិទ្យាល័យ Zurich ស្តីពី ជំនាញស្រាវជ្រាវច្បាប់ និងបានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការជាមួយភាគីបារាំង(APF) និងដៃគូនានា នៅសាធារណរដ្ឋបារាំង ព្រមទាំងអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍សមាគមអគ្គលេខាធិការសភាពិភពលោក(ASGPF)នៅប្រទេសសេណេហ្គាល់

និងចូលរួមក្នុងពិធីបើកមហាសន្និបាតនៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង(ASGPF) នៅព្រះរាជាណាចក្រម៉ារ៉ុក

–ឯកឧត្តម លីម ប៊ុនហុក អគ្គលេខាធិការរងព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិចំនួន០៣លើក

–បានរៀបចំជូនប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីសភានៃព្រះរាជាណាចក្រថៃឡង់ដ៍ និងព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង

–បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU)ចំនួន០៤លើក ជាមួយខុទ្ទកាល័យរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម, មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ, វិទ្យាស្ថានស្រាវជ្រាវ KING PRAJADHIPOK INSTITUTION (KPI) នៃព្រះរាជាណាចក្រថៃឡង់ដ៍ និងរាជបណ្ឌិត្យសភាកម្ពុជា

–បានរៀបចំចាត់ចែង និងផ្តល់សេវាក្នុងពិធីនានា រួមមាន៖

+ពិធីប្រគល់-ទទួលជំនួយសម្ភារវេជ្ជសាស្ត្រពីអង្គការចែករំលែកសង្គ្រោះអាយុជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ព្រមទាំងបានរៀបចំពិធីប្រគល់ឱសថ និងបរិក្ខារពេទ្យ ជូនដល់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យគន្ធបុប្ផា(ភ្នំពេញ) មន្ទីរពេទ្យគន្ធបុប្ផា(សៀមរាប) និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា ខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា

+ពិធីប្រគល់-ទទួលអំណោយឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ចំនួន៧០ម៉ឺនតេស្ត ដែលជាជំនួយរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នៅវិមានព្រឹទ្ធសភា

+ពិធីបំពាក់គ្រឿងឥស្សរិយយសរបស់គណៈប្រតិភូបេសកកម្មសុឆន្ទៈនៃសភាប្រើភាសាបារាំង(APF) ជូនឯកឧត្តមប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា

+កម្មវិធីផ្សព្វផ្សាយសៀវភៅដែលផ្តល់ដោយមជ្ឈមណ្ឌលវប្បធម៌ចិន និងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន នៅវិមានព្រឹទ្ធសភា។

–បានរៀបចំជំនួយស្មារតី សុន្ទរកថា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សម្រាប់ពិធីជួបសវនាការជាមួយគណៈប្រតិភូជាន់ខ្ពស់សភានៃប្រទេសជាមិត្ត និងពិធីបើកមហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤៣

–បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតបារាំង, ស្ថានទូតកូរ៉េ, ស្ថានទូតសិង្ហបុរី, ស្ថានទូតចិន, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតហ្វីលីពីន, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការសហប្រជាជាតិនៅកម្ពុជា, អង្គការមូលនិធិអាស៊ី, អង្គការ UNICEF,

អង្គការតម្លាភាពកម្ពុជា (TI Cambodia), មូលនិធិ Gong Xiang, មូលនិធិសន្តិភាពដើម្បីអភិវឌ្ឍ, រាជ្យបណ្ឌិតសភាកម្ពុជា, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា(CDC), សាលាភូមិន្ទរដ្ឋបាល, សាកលវិទ្យាល័យប៊ែលធីអន្តរជាតិ, សាកលវិទ្យាល័យកម្ពុជា, មជ្ឈមណ្ឌលសភាអាស៊ី(PCA), មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ(HRD), វិទ្យាស្ថានជាតិសង្គមកិច្ច, វិទ្យាស្ថានProseth, វិទ្យាស្ថានSunrise, វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺត(RWL), វិទ្យាស្ថានSalaCyber, វិទ្យាស្ថាន DataU Academy, វិទ្យាស្ថាន CamKPI Professional Academy, វិទ្យាស្ថានMUT International College, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានខុងជឺ, វិទ្យាស្ថានGreatX Center, វិទ្យាស្ថានជាតិ ប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT), ភ្នាក់ងារសង្គមព័ត៌មានជាតិ(NIA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, បណ្ណាល័យអាស៊ី-អឺរ៉ុប និងបណ្ណាល័យជាតិ, ក្រុមហ៊ុនHUAWEI, ក្រុមហ៊ុន KOHA, ក្រុមហ៊ុនCambodia Hosting និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

### ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

–បានសហការ និងសម្របសម្រួលការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩(ដូសជំរុញ) ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា, ថ្នាក់ដឹកនាំ សមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ, ទីប្រឹក្សារបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រួមទាំងក្រុមគ្រួសារប្រកបដោយជោគជ័យ

–បានរៀបចំពិធីសម្ពោធស្វាគសមិទ្ធផលលើការជួសជុលអគារក្រហម និងបណ្ណាល័យព្រឹទ្ធសភា ដែលជាជំនួយរបស់ស្ថានទូតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា

–បានទទួលសម្ភារឧបករណ៍បច្ចេកទេសព័ត៌មានវិទ្យា ជំហានទី១ ក្រោមការឧបត្ថម្ភគាំទ្ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

–បានសហការរៀបចំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ដែលផុតសុពលភាព ខូច បាត់ និងកែតម្រូវថ្មី) ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤៥២ប័ណ្ណ

–បានរៀបចំប្រកាសទ្រព្យសម្បត្តិ និងបំណុលជូនបុគ្គលជាប់កាតព្វកិច្ចតាមរបប០២ឆ្នាំ សម្រាប់ឆ្នាំ២០២៣

–បានប្រជុំស្តីពី ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយ (លើកទី១ និងទី២) សម្រាប់អនុវត្តច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ផ្ទៃក្នុង និងជាមួយគណៈកម្មការទី២ព្រឹទ្ធសភា

–បានប្រជុំក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានប្រជុំការងារលទ្ធកម្មនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានប្រជុំស្តីពី ការងារគ្រប់គ្រងបុគ្គលិកនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រជុំពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្នុង

-បានប្រជុំការងារជាមួយអង្គភាពកិច្ចការសង្គម ដើម្បីពិនិត្យការអនុវត្តការងារ តួនាទី ភារកិច្ចរបស់អង្គភាពកិច្ចការសង្គម

-បានប្រជុំបូកសរុបលទ្ធផលការងាររបស់សមាគមសង្គហៈមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានប្រជុំពិនិត្យលើសេចក្តីព្រាងកម្មវិធីផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០២២

-បានប្រជុំពិនិត្យផែនការមេស្តីពី បរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិច (ឆ្នាំ២០២២-២០៣០)

-បានប្រជុំត្រួតពិនិត្យពិភាក្សាការងារសំខាន់ៗ និងលើកទិសដៅការងារសម្រាប់អនុវត្តបន្តរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានផ្សព្វផ្សាយសេចក្តីជូនដំណឹងដល់សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាស្តីពី ការចូលរួមបំពេញកាតព្វកិច្ចបរិច្ចាគជូនមូលនិធិគន្ធបុប្ផាសម្រាប់ឆ្នាំ២០២២

-បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មីៗ

**៤.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ**

-បានរៀបចំរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១ និងការបែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បានរៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភា ប្រចាំឆ្នាំ២០២២ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បានរៀបចំផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (ឆ្នាំ២០២៣-២០២៥) និងគម្រោងថវិកាឆ្នាំ២០២៣របស់ព្រឹទ្ធសភា

-បានរៀបចំគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២៣ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បានការពារគម្រោងថវិកាព្រឹទ្ធសភា ឆ្នាំ២០២៣ ក្នុងកម្រិតបច្ចេកទេស និងកម្រិតនយោបាយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានបោះផ្សាយអាណត្តិឥណទានបន្ថែមសម្រាប់ចំណាយការបំពេញទស្សនកិច្ចផ្លូវការនៅ

សាធារណរដ្ឋកូរ៉េ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

-បានចូលរួមប្រជុំក្រុមកំណែទំរង់ហិរញ្ញវត្ថុ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន៤០លើក

-បានរៀបចំថវិកាកម្មវិធីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងការចាប់ផ្តើមចូលរួមអនុវត្តតាមប្រព័ន្ធ FMIS

-បានរៀបចំសមាសភាព(PFMRP) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានបើកប្រាក់បៀវត្សប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០២២ ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានដោះស្រាយថវិកាសម្រាប់រៀបចំដង្វាយថ្វាយ**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម

-បានតាមដានគោលការណ៍ និងព័ត៌មានទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-បានដេញថ្លៃការផ្គត់ផ្គង់ ការបោះពុម្ព ប្រេងឥន្ធនៈ សម្ភារការិយាល័យ សម្ភារអនាម័យ និងឯកសណ្ឋានមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

-បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងកំណត់បង្ហាញចំនួន១,០៣២ច្បាប់

-បានធ្វើប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៨២ប័ណ្ណ

-ការតែងតាំងមុខតំណែងថ្មីមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានរៀបចំបញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវបានវាយតម្លៃតម្លើងថ្នាក់បៀវត្ស តាមវេនជ្រើសរើស និងវេនអតីតភាពសម្រាប់ឆ្នាំ២០២២

-បានធ្វើបញ្ជីរាយនាមនិវត្តជន និងមន្ត្រីរាជការបាត់បង់សម្បទាវិជ្ជាជីវៈនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានធ្វើជំរឿនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឆ្នាំ២០២២

-បានធ្វើជំរឿនស្ថិតិ និងសញ្ញាបត្រមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើបច្ចុប្បន្នភាពប្រវត្តិរូប និងពិពណ៌នាការងាររបស់មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានទទួលអាហារូបករណ៍ពីស្ថានទូតចិន ស្ថានទូតឥណ្ឌា និងសាកលវិទ្យាល័យនានាចំនួន

៣៤កន្លែង សិក្ខាកាមចូលរួមចំនួន១៧នាក់

-បានបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសចំនួន៤៨វគ្គ មានសិក្ខាកាមចូលរួមចំនួន ៨៩៦នាក់ និងក្រៅប្រទេសចំនួន១១វគ្គ មានសិក្ខាកាមចូលរួមចំនួន១៣នាក់ ព្រមទាំងសិក្ខាសាលាក្នុង និងក្រៅប្រទេសចំនួន២១លើក មានសិក្ខាកាមចូលរួមចំនួន៥៨១នាក់

-បានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សានៅក្នុង និងក្រៅប្រទេសចំនួន១៣លើក

-បានធ្វើរបាយការណ៍វាយតម្លៃការធ្វើបទបង្ហាញរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៃវគ្គបណ្តុះបណ្តាលនានាចំនួន១៣វគ្គ ស្មើនឹង២៥៧លើក

-បានធ្វើផែនការបណ្តុះបណ្តាលធនធានមនុស្សឆ្នាំ២០២៣

-បានទទួលលិខិតចូលចំនួន៦,៨៥៦ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៤,២៨៩ច្បាប់

-បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការថែរក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការថែរសន្តិសុខ និង សណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

-បានបាញ់ថ្នាំសម្លាប់មេរោគតាមអគារនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបាន សហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺគ្រុនចាញ់ មកបាញ់ថ្នាំសម្លាប់សត្វមូស និងសត្វ ល្អិតក្នុងបរិវេណព្រឹទ្ធសភា

-បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងដាំដើមឈើចំនួន១៣៧លើក

-បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

-បានទទួលរថយន្តប្រើប្រាស់ថាមពលអគ្គិសនីចំនួន០២គ្រឿង សម្រាប់គាំពារបរិស្ថាន

-បានរៀបចំផ្ទេរខុទ្ទកាល័យអគ្គលេខាធិការរង អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធា-រណៈទៅកាន់ទីតាំងថ្មី

-បានសង់ឃ្លាំង និងបន្ទប់ស្នាក់នៅរបស់អង្គភាពសន្តិសុខឡើងវិញនៅខាងក្រោយអគារE ព្រមទាំង ធ្វើធ្នើរដែកដាក់សម្ភារនៅបន្ទប់ Studio ក្រោមអគារក្រហម

-បានជួសជុលកែលម្អ និងបំពាក់សម្ភារៈ អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាទាំងបី, អគារ ក្រហម, សាលប្រជុំពេញអង្គ, អគារអតីតនាយកដ្ឋានព័ត៌មានវិទ្យា, អគារអតីតខុទ្ទកាល័យអគ្គ-លេខាធិការរង, ខុទ្ទកាល័យអគ្គលេខាធិការរងថ្មី និងជំនួយការ, អគារបណ្ណាល័យ, អគារអគ្គនាយកដ្ឋាន ព័ត៌មាន និងទំនាក់ទំនងសាធារណៈ, នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ, បន្ទប់សមាជិកព្រឹទ្ធសភា និងបន្ទប់ប្រជុំរបស់គណៈកម្មការទី៣, បន្ទប់សារព័ត៌មានក្រោមអគារក្រហម, បន្ទប់កាមេរ៉ាសុវត្ថិភាព

របស់អង្គភាពសន្តិសុខ, ដំបូល សំយ៉ាប ពិដាននៅតាមអគារនានា និងសាលប្រជុំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, បន្ទប់ទឹកសាលខាងជើង សាលខាងត្បូង អគារគណៈកម្មការទី១០ អគារជប៉ុន និងអគារABC, លាបថ្នាំអគារជប៉ុន អគារF, ប្រព័ន្ធអគ្គិសនី, ប្រព័ន្ធជណ្តើរយន្តនៅអគារសមាជិកព្រឹទ្ធសភា, កញ្ចុះអង្គុយនៅក្រោមដើមជ្រៃ, ការរៀបចំបន្ទប់គ្រូពេទ្យ និងបំពាក់សម្ភារបរិក្ខារសម្រាប់ថែទាំសុខភាពបឋម ជូនសមាជិកព្រឹទ្ធសភា, ការរៀបចំកន្លែងធ្វើការជូនក្រុមសិក្សាស្រាវជ្រាវទូទៅ, ការរៀបថ្មភ្នំនៅជុំវិញអគារសាលប្រជុំពេញអង្គ, ការរៀបចំថ្មម៉ាបនៅខាងមុខអគារថ្នាក់ដឹកនាំព្រឹទ្ធសភា, ប្តូរកែងអូតូទ្វារដែកនៅអគ្គាធិការ នាយកដ្ឋានហិរញ្ញវត្ថុ អង្គភាពលទ្ធកម្ម និងអគារ DEF, បំពាក់ផ្ទាំងគំនូរនៅសាលសាឡុងធំ និងសាលអចិន្ត្រៃយ៍, កែលម្អពេងផ័ត្រធំនៅសួនម៉ាឡេស៊ី អាងចិញ្ចឹមត្រី, ស្តារប្រព័ន្ធលូដាក់ខ្មោះមុខទឹកភ្លៀង ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា

–បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក, ត្រួតពិនិត្យជណ្តើរយន្ត ត្រួតពិនិត្យសត្វកណ្តៀរ, ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២,៧៥៣គ្រឿង/លើក

–បានរៀបចំរបាយការណ៍ស្ថានភាពទ្រព្យសម្បត្តិរដ្ឋរបស់ព្រឹទ្ធសភាប្រចាំឆមាសទី១ ឆ្នាំ២០២២ និងចុះត្រួតពិនិត្យ ផ្ទៀងផ្ទាត់សារពើភណ្ឌសម្ភារនៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

–បានផលិតរបាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ចំនួន០២លើក

–បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមករា ដល់ខែធ្នូ, ប្រចាំឆមាសទី១ ប្រចាំនព្វមាស និងប្រចាំឆ្នាំ២០២២ ទូលថ្វាយ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

–បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមករា ដល់ខែធ្នូ, ប្រចាំឆមាសទី១, ប្រចាំនព្វមាស និងប្រចាំឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា

–បានធ្វើរបាយការណ៍ស្តីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានទាំង៥ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី១, ទី២, ទី៣ និងទី៤ ឆ្នាំ២០២២ ចំនួន០៤លើក។

**៤.២-ការងារសេវាច្បាប់៖**

-បានទទួលសេចក្តីព្រាងច្បាប់ចំនួន១៤ច្បាប់ ពីរាជរដ្ឋាភិបាល និងរដ្ឋសភា

-បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗចំនួន៣,៦១២ច្បាប់

-បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន៧៨ច្បាប់ និងបានផ្សព្វផ្សាយព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស របាយការណ៍ និងលិខិតផ្សេងៗចំនួន ៥៤៥ច្បាប់

-បានចងក្រង និងបោះពុម្ពសៀវភៅលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥

-បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាល នីមួយៗ

-បានធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ទូទាំងប្រទេស ជូនក្រុម សមាជិកព្រឹទ្ធសភា

-បានធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០២២-២០២៤)។

**៤.៣-ការងារស្រាវជ្រាវ៖**

-បានផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន១៤ច្បាប់

-បានផលិតឯកសារស្រាវជ្រាវពាក់ព័ន្ធនឹងដំណើរការអនុវត្ត និងការវិវត្តរបស់ច្បាប់ចំនួន២៣ច្បាប់

-បានសិក្សាស្រាវជ្រាវ បកប្រែ ចងក្រង និងផលិតឯកសារផ្សេងៗពាក់ព័ន្ធនឹងច្បាប់ សេដ្ឋកិច្ច សង្គម ថវិកា និងវិស័យផ្សេងៗចំនួន៣៥អត្ថបទ

-បានតាមដាន និងចងក្រងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា (ឆ្នាំ២០២១-២០៣៥)ចំនួន០៨អត្ថបទ

-បានកសាងឯកសារស្រាវជ្រាវ តាមដានការងារកំណែទម្រង់ និងគោលនយោបាយនានារបស់ រាជរដ្ឋាភិបាលក្នុងអំឡុងពេលកូវីដ-១៩ ចំនួន០៤អត្ថបទ

-បានផលិត និងផ្សាយព្រឹត្តិបត្រព័ត៌មានស្រាវជ្រាវសេដ្ឋកិច្ច និងសង្គមចំនួន០៤អត្ថបទ

-បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៩៩៨អត្ថបទ

-បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០២២ ចំនួន៤៨ច្បាប់។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

–បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

–បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន២២លើក

–បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលកុំព្យូទ័រ ម៉ាស៊ីនPrinter Scanner, ប្តូរ Toner Drume និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៩៥២គ្រឿង/លើក។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាចំនួន២,៣៧២ប្រធានបទ

–បានបន្តបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ និងIpad ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៤០គ្រឿង

–បាននឹងកំពុងសិក្សា និងរៀបចំប្រព័ន្ធបណ្ណសារដ្ឋានអេឡិចត្រូនិច បណ្ណាល័យអេឡិចត្រូនិច និងកម្មវិធីទូរស័ព្ទ ដើម្បីផ្សព្វផ្សាយពីដំណើរការ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសាធារណជន

–បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន១,៩៤៦ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ អ៊ុតក្របសៀវភៅ បញ្ជូនសៀវភៅទៅសេវាអ្នកអាន បិទប័ណ្ណខ្ចី និងសងសៀវភៅចំនួន១,៤៩៦ក្បាល

–បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៥៤២លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២៤៥លើក

–បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន១៨,៦១០ប្រធានបទ

–បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**៤.៥-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

–បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៣១៨លើក

–បានកសាងជំនួយស្មារតី សុន្ទរកថា និងបកប្រែឯកសារនានា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន ១៧០ច្បាប់

–បានរៀបចំ និងបញ្ជូនសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ និងរំលែកទុក្ខ

របស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់នៃបណ្តាប្រទេសជាមិត្ត ថ្នាក់ដឹកនាំអង្គការអន្តរសភា និងស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជាចំនួន៨៤លិខិត

–បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១១៨ច្បាប់

–បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែមករា ដល់ខែវិច្ឆិកា និងប្រចាំឆ្នាំ២០២២ ចំនួន១២ច្បាប់។

**៤.៦-ការងារអគ្គាធិការដ្ឋាន៖**

–បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០២២ ចំនួន២២៨លើក

–បានប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

–បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

–បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

–បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

–បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃចំនួន២៩០លើក ប្រចាំសប្តាហ៍ចំនួន ៤៨លើក និងប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០២២

–បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែមករា ដល់ខែធ្នូ និងប្រចាំឆ្នាំ២០២២។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

–បានតុបតែងលម្អ និងរៀបចំពិធីសូត្រមន្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

–បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៥០៨ច្បាប់ ស្មើនឹង១,៦១៦នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន៦២ច្បាប់ ស្មើនឹង៦២នាក់

–បានសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ ជួបគ្រោះថ្នាក់ចរាចរណ៍ លំហែមាតុភាព និងនិវត្តជន

នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤៩នាក់

-បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២,៧៩២លីត្រ ជូនអង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា

-បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៦,២០០លើក

-បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន១,០៧១សំណើ

-បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៤៣១លើក មានអ្នកចូលរួមចំនួន១២,៨២៣នាក់

-បានថតចម្លងឯកសារចំនួន៥៣,២៦៣ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន១,១៩៥ក្បាល អស់ក្រដាសចំនួន៥៧១,២៣៩សន្លឹក

-បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន ២,១៧០លើក ស្មើនឹង៥,២៩៩នាក់ៗ បានបង់ពន្ធផ្លូវរថយន្តសម្រាប់ឆ្នាំ២០២២ និងយករថយន្តទៅឈៀក

-បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ និងចងបដា ពាក្យស្លោកចំនួន១៤៣លើក

-បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន១៥២លើក

-បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន ២,៨៨២លើក

-បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន២៥៦លើកៗ

## III-**ទិសដៅការងារឆ្នាំ២០២៣**

### ១- **មុខងារនីតិកម្ម**

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ៗ

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

–ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មក្នុងរយៈពេលវិស្សមកាល ពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ ដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

–ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយ ប្រជាពលរដ្ឋនៅមូលដ្ឋាន និងអាជ្ញាធរដែនដី ព្រមទាំងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាម បណ្ដាខេត្ត ក្រុងនានា

–ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំ វេទិកា សិក្ខាសាលា ពិធីបុណ្យជាតិ-អន្តរជាតិ និងពិធីសាសនា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

–ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអង្គទូតនានា នៃប្រទេសជាមិត្ត

–បង្កើនសហប្រតិបត្តិការតំបន់ និងអន្តរជាតិ តាមរយៈការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ

–ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយដៃគូអភិវឌ្ឍន៍

–ជំរុញកម្មវិធីបណ្ដុះបណ្ដាលមន្ត្រីក្នុង និងក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគី ជាមិត្ត និងដៃគូផ្សេងៗទៀត

–ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

–សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ និងបន្តស្វែងរកជំនួយសម្រាប់ អភិវឌ្ឍន៍ស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន

–ត្រៀមរៀបចំជូនសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការព្រឹទ្ធសភា ចូលរួម ប្រជុំ ក្នុងកិច្ចប្រជុំតំបន់ និងអន្តរជាតិ កិច្ចប្រជុំវេទិកា (AIPA, IPU, APF, APA, APPF, CLV, ASGP)

–ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី (PCAsia)

–បន្តស្រាវជ្រាវ បកប្រែ និងផលិតឯកសារជំនួយស្មារតី សុទ្ធរកថាជូនថ្នាក់ដឹកនាំ សមាជិក

សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិ ក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា

–បង្កើនការយកចិត្តទុកដាក់អនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន តាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការដៃគូអភិវឌ្ឍន៍ថ្មីៗបន្ថែមទៀត។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

–ត្រៀមរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ និងការបែងចែកឥណទានឆ្នាំ២០២៣ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

–បន្តវិចារណកម្មថវិកា៖ សន្សំសំចៃ និងអាទិភាពចំពោះតែការងារចាំបាច់បន្ទាន់ និងប្រញាប់បំផុត

–ត្រៀមរៀបចំបំពាក់គ្រឿងឥស្សរិយយសជូនសមាជិកព្រឹទ្ធសភា នៅចុងនីតិកាលទី៤

–បន្តតាមដាន និងសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា គម្រោងស្នើកសាងអគារថ្មី១ខ្នង គម្រោងស្តីពីការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន សម្រាប់ព្រឹទ្ធសភា និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្ត សម្រាប់នីតិកាលថ្មីខាងមុខ

–ត្រៀមរៀបចំយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល(២០២៤-២០២៦) និងរៀបចំគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២៤

–ត្រៀមការពារគម្រោងថវិកាឆ្នាំ២០២៤ ក្នុងកម្រិតបច្ចេកទេស និងកម្រិតនយោបាយ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

–ត្រៀមបែងចែកឥណទានឆ្នាំ២០២៤ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល និងរៀបចំរបាយការណ៍ទូទាត់ថវិកាឆ្នាំ២០២៣ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

–ត្រៀមបញ្ចប់ការសិក្សាគម្រោង និងប្លង់សាងសង់សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មី និងប្លង់សាងសង់របងថ្មីខាងមុខព្រឹទ្ធសភា

–ត្រៀមធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៩ និងទី១០ ឱ្យបានល្អ និងទាន់ពេលវេលា

–ត្រៀមរៀបចំបែបបទស្នើសុំជំនួយពីសភានៃប្រទេសជាមិត្ត សម្រាប់ការសាងសង់អគារសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សាងសង់របងថ្មីមុខព្រឹទ្ធសភា រួមទាំងការជួសជុលកែលម្អអគារសាលទទួលភ្ញៀវជាតិ-អន្តរជាតិ និងអគារសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បច្ចុប្បន្ន

–ត្រៀមរៀបចំបែបបទដំឡើងមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំឆ្នាំ២០២៣ ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋព្រឹទ្ធសភា និងសារពើភ័ណ្ឌធនធានមនុស្ស

-ត្រៀមរៀបចំឯកសារគោលស្តីពី តួនាទី ភារកិច្ច របស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារពិពណ៌នាការងារ និងបញ្ជាក់ពីសមត្ថភាពធ្វើការងាររបស់មន្ត្រីរាជការ

-ត្រៀមរៀបចំកសាងឯកសារបូកសរុបសមិទ្ធផលការងារ នីតិកាលទី៤ របស់ព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មីស្តីពី ការផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការមានស្នាដៃឆ្នើម ការវាយតម្លៃការបំពេញការងាររបស់មន្ត្រីរាជការ និងការគ្រប់គ្រងធនធានមនុស្ស

-ការដំឡើងប្រាក់បំណាច់មុខងារដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២៣

-ត្រៀមធ្វើរបាយការណ៍តាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការប្រតិបត្តិរបស់អង្គភាពចំណុះអគ្គនាយកដ្ឋានទាំង៥ ប្រចាំត្រីមាសទី១, ទី២, ទី៣ និងទី៤ ឆ្នាំ២០២៣

-បន្តរៀបចំផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥ របស់ព្រឹទ្ធសភា និងការត្រៀមជាបណ្តើរៗ ការរៀបចំជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារការិយាល័យធ្វើការ រួមទាំងការបំពាក់សម្ភារៈឧបករណ៍ថ្មី និងការត្រៀមលក្ខណៈសម្បត្តិជាមុនការបើកសម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី៥

-ត្រៀមធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០ ឱ្យបានទាន់ពេលវេលា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗ

-ត្រៀមបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមវគ្គបណ្តុះបណ្តាលកិច្ចការសភានៅក្រៅប្រទេស

-ធ្វើបច្ចុប្បន្នភាពផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល១០ឆ្នាំ (២០២២-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គ្រប់អង្គភាពជំរុញការអនុវត្តផែនការប្រតិបត្តិឱ្យមានប្រសិទ្ធផលខ្ពស់

-ត្រៀមអនុវត្តផែនការបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២៣

-ត្រៀមបើកវគ្គបណ្តុះបណ្តាលលើមុខជំនាញដែលជាតម្រូវការចាំបាច់របស់ស្ថាប័ន

-ត្រៀមរៀបចំផលិតវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## IV-**សេចក្ដីសន្និដ្ឋាន**

ក្នុងឆ្នាំ២០២២នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអនុវត្តការងារសម្រេចបានលទ្ធផលកើនឡើងលើមុខងារទាំងឋជាងឆ្នាំ២០២១។ លទ្ធផលទាំងនេះ ជាសូចនាករនៃការគ្រប់គ្រង ដឹកនាំ និងជំនាញរបស់មន្ត្រីក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

ដើម្បីបង្កើនប្រសិទ្ធផលអោយកាន់តែល្អប្រសើរថែមទៀត អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបើកវគ្គបណ្ដុះបណ្ដាល ដើម្បីពង្រឹងសមត្ថភាពលើការងារគ្រប់គ្រង ដឹកនាំ និងប្រមូលធាតុចូលក្នុងការកសាងផែនទីបង្ហាញផ្លូវឆ្ពោះទៅសម្រេចឱ្យបានផែនការយុទ្ធសាស្ត្រ (២០២១-២០៣០) សម្រាប់ការអភិវឌ្ឍស្ថាប័នព្រឹទ្ធសភាឱ្យក្លាយជាសភាទំនើប។

ស្របតាមបរិបទនៃការវិវត្តថ្មី អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានដាក់ចេញវិធានការគោលនយោបាយនានា ជាពិសេសការអនុវត្តគោលនយោបាយ "ថវិកាតិច សកម្មភាពច្រើន" ប្រកបដោយជោគជ័យ ដោយធានាបាននិរន្តរភាព និងប្រក្រតីភាពក្នុងការអនុវត្តថវិកាឆ្នាំ២០២២។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការ និងការណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងល្អប្រសើរ។

ថ្ងៃអង្គារ ៤រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣

**អគ្គលេខាធិការ**

**អ៊ុំ សារឹទ្ធ**